ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ



ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
អគ្គនាយកដ្ឋានបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន


លេខ:......១៨៦................ប.គ.ព

ថ្ងៃអង្គារ ៧រោច ខែជេស្ឋ ឆ្នាំច សំរឹទ្ធិស័ក ព.ស២៥៦២
រាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែមិថុនា ឆ្នាំ២០១៨

# សេចក្ដីជូនដំណឹង
## ស្ដីពីការជ្រើសរើសនិស្សិតចូលរួមការប្រកួតប្រជែងផ្នែកសន្ដិសុខ បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន "Cambodia Cyber Contest 2018"

អគ្គនាយកដ្ឋានបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មានមានកិត្តិយសសូមធ្វើការជូនដំណឹងស្ដីពីការប្រកួតប្រជែងផ្នែកសន្តិសុខបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន **"Cambodia Cyber Contest"** សម្រាប់និស្សិត នាថ្ងៃទី ២៦ ខែមិថុនា ឆ្នាំ ២០១៨ ហើយអ្នកដែលទទួលបានជ័យលាភីចំនួនពីរ(០២)រូប នឹងត្រូវបានបញ្ជូនទៅធ្វើការប្រកួតបន្តថ្នាក់តំបន់នៅប្រទេសសិង្ហបុរីនៅខែកញ្ញា ឆ្នាំ២០១៨ ខាងមុខ។ ការប្រកួតប្រជែង Cambodia Cyber Contest គឺជាប្រភេទនៃការប្រកួតប្រជែងផ្នែកសន្តិសុខបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន ឬអាចហៅថាជាការប្រកួត Capture The Flag ប្រភេទ Jeopardy ដែលមានទម្រង់ជាការឆ្លើយនូវសំណួរដើម្បីទទួលបានពិន្ទុ។ ការប្រកួតប្រជែងនេះមានសំណួរចាប់ពីកម្រិតងាយស្រួលរហូតទៅដល់កម្រិតពិបាកដែលទាមទារនូវសមត្ថភាពនិងចំណេះដឹងមូលដ្ឋានមួយចំនួនដូចជា Binary, Cryptography, Cracking, Digital Forensics, Encode, Programing និង Web ដើម្បីមានលទ្ធភាពក្នុងការដោះស្រាយសំណួរ។

សូមបញ្ជាក់ថាកម្មវិធីប្រកួតប្រជែងខាងលើគឺសម្រាប់តែនិស្សិតស្ថិតក្នុងការសិក្សាតែប៉ុណ្ណោះ ដោយការប្រកួតនេះគឺសំដៅលើកកម្ពស់សមត្ថភាពជំនាញ និងវាស់ស្ទង់ចំណេះដឹងដើម្បីជំរុញការអភិវឌ្ឍវិស័យសន្តិសុខបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន ក្នុងខណៈពេលដែលជំនាញក្នុងវិស័យនេះមានតម្រូវការយ៉ាងខ្លាំងទាំងក្នុងប្រទេស ក្នុងតំបន់ និងពិភពលោក ។

បេក្ខជនដែលមានចំណាប់អារម្មណ៍ចូលរួមក្នុងការប្រកួតខាងលើ អាចធ្វើការចុះឈ្មោះបានតាមរយៈគេហទំព័រ http://contest.camcert.gov.kh អោយបានមុនថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៨ ក្រុមការងារគ្រប់គ្រងការចុះឈ្មោះបេក្ខជននឹងធ្វើការទាក់ទងទៅបេក្ខជនដើម្បីផ្ដល់ដំណឹងអំពីការប្រកួត។ សម្រាប់ព័ត៌មានបន្ថែមទំនាក់ទំនងមកកាន់លេខទូរស័ព្ទ ០១៦ ៨៥១ ៦៧៨ ឬអ៊ីម៉ែល ann-kim@mptc.gov.kh ។

ប.គ.ព


អគារលេខ១៣ មហាវិថីព្រះមុនីវង្ស (៩៣)
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ: (៨៥៥)២៣ ៧២២ ៥១៨
អ៊ីម៉ែល: vet-chun@mptc.gov.kh